**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2013, 14:06
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង សាធារណៈ/Public
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# សំណើសុំកោះហៅសាក្សី ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរ

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**
សុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
Joshua ROSENSWEIG
Forest ONEILL GREENBERG
Elizabeth BUDNITZ

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**
ជា លាង
Andrew CAYLEY

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្តី នួន ជា (ក្រុមមេធាវីការពារក្តី) សូមដាក់សំណើបន្ទាន់ ("សំណើ") ដោយអនុលោមតាមវិធាន ៩២ និង ៨៧ (៤) នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីទាំងអស់ដែលសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា យកមកសំអាងដើម្បីបញ្ជាក់ពីអត្ថិភាពនៃការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាអតីតមន្ត្រី និងទាហានសាធារណរដ្ឋ៖

## I. ប្រវត្តិនីតិវិធី

1. កាលពីថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ និងថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ ដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានដាក់បញ្ជីចុងក្រោយនៃចម្លើយសាក្សី និងពាក្យបណ្តឹង ជាភ័ស្តុតាង។ កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តី បានជំទាស់ទៅនឹងចម្លើយទាំងនោះភាគច្រើន ក្នុងនោះមានភ័ស្តុតាងទាក់ទងនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាអតីតមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ[1]។

2. កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈបញ្ជាក់ថាអង្គជំនុំជម្រះ នឹងចេញសេចក្តីសម្រេចចុងក្រោយអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវផ្តល់ស្តាប់ចម្លើយក្នុងសំណុំរឿង០០២/០១ នៅពេលខ្លីខាងមុខ និងបញ្ជាក់ថាភាគីនឹងត្រូវបានផ្តល់ឱកាសដើម្បីលើកឡើងអំពីបញ្ហាថ្មីពាក់ព័ន្ធនឹងសាក្សីទាំងនេះនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនាពេលខាងមុខ[2]។ កាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣ មន្ត្រីច្បាប់ជាន់ខ្ពស់បានបញ្ជូនបញ្ជីសាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ និងសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/ ០១ មុនពេលអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចដោយមានសំអាងហេតុពាក់

---

1. *សូមមើល* ឯកសារលេខ **E223/2/8/1.2** "ឧបសម្ព័ន្ធ ១៖ ការជំទាស់របស់ នួន ជា ចំពោះបញ្ជីឯកសារតាមវិធាន ៨០(៣)(ឃ) របស់សហព្រះរាជអាជ្ញា - ឧបសម្ព័ន្ធ ១២", លេខ ២៤៧។ *សូមមើល ផងដែរ* ឯកសារលេខ **E223/2/8** "ការជំទាស់ទៅនឹងសំណើសុំដាក់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកនៅចំពោះមុខអង្គជំនុំជម្រះ" ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣; ឯកសារលេខ **E223/2/8/1** "ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងចម្លើយ និងប្រតិចារឹកនានា" ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣។
2. ឯកសារលេខ **E288** អនុស្សរណៈពីចៅក្រមប្រធាន និល ណុន ផ្ញើជូនភាគីនានា, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣, កថាខណ្ឌ ៣។

ព័ន្ធនឹងបញ្ហានេះ។

3. ក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើឡើងកាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ និងក្នុងសារណាជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធ ក្រុមមេធាវីការពារក្តី ស្នើសុំស្តាប់ចម្លើយសាក្សីចំនួន៦រូប ដែលជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ៖ សាក្សីចំនួន៥រូប ទាក់ទងទៅនឹងភ័ស្តុតាងមូលដ្ឋាននៃបទឧក្រិដ្ឋកម្ម និងសាក្សីមួយរូបទៀត TCW-223 ទាក់ទងទៅនឹងគោលនយោបាយបក្សកុំម្មុយនីស្តកម្ពុជានៃការកំណត់មុខសញ្ញាអតីតទាហាន និងមន្ត្រីរបបសាធារណរដ្ឋខ្មែរ[3]។ កាលពីថ្ងៃទី ១៩ ខែ មិថុនា អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចកោះហៅសាក្សីមួយរូបក្នុងចំណោមសាក្សីទាំងនោះ និងសាក្សីចំនួនពីររូប ដែលត្រូវបានស្នើដោយសហព្រះរាជអាជ្ញាទាក់ទងនឹងអត្ថិភាពនៃការចោទប្រកាន់អំពីគោលនយោបាយនៃការសម្លាប់អតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ និងសាក្សីមួយរូបទៀតទាក់ទងនឹងតួនាទីរបស់ខៀវ សំផន[4]។

4. ក្នុងកិច្ចប្រជុំរៀបចំសវនាការ លោកប្រធានអង្គជំនុំជម្រះសាលាដំបូង ក៏បានយោងផងដែរទៅដល់សំណើដែលមិនទាន់ដោះស្រាយរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់ចម្លើយជាលាយលក្ខណ៍អក្សរជាភ័ស្តុតាង។ លោកប្រធានអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថាសេចក្តីសម្រេចមួយ នឹងត្រូវចេញក្នុងរយៈពេលពីរបីសប្តាហ៍ខាងមុខ ដោយបន្ថែមថា "ចម្លើយជាលាយលក្ខណ៍អក្សរចំនួនប្រមាណ ១.៥០០ នឹងទទួលបានចំណាត់ប្រភេទ E3 នៅពេលដែលសេចក្តីសម្រេច និងឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងសេចក្តីសម្រេច រៀបចំរួចរាល់ហើយ[5]"។ ក្រុមមេធាវីការពារក្តី កត់សម្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានស្នើដាក់ចម្លើយជាលាយលក្ខណ៍អក្សរ និងពាក្យបណ្តឹងចំនួន ១.៥៧២ ជាភ័ស្តុតាង[6]។ ក្រុមមេធាវីការពារក្តី

---

3. ឯកសារលេខ **E291** "សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ" ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

4. ឯកសារលេខ **E292** សារអេឡិកត្រូនិចពីអ្នកស្រី Susan Lamb ផ្ញើជូនភាគីនានា, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣។

5. ឯកសារលេខ **E1/207.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ២៦:១១ ដល់ ១២ (ភាសាអង់គ្លេស)។

6. ឯកសារលេខ **E278.3** "ឧបសម្ព័ន្ធ ១២ កែប្រែ៖ ចម្លើយរបស់សាក្សី" ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣; ឯកសារលេខ **E278.4** "ឧបសម្ព័ន្ធ ១៣ កែប្រែ៖ បណ្តឹង" ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣; ឯកសារលេខ **E223/2/7.2** "ឧបសម្ព័ន្ធ ១៖

សន្និដ្ឋានថាអង្គជំនុំជម្រះ បានសម្រេចទទួលយកភាគច្រើននៃឯកសារទាំងនោះជាភ័ស្តុតាង។

## I. សាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា

5. ឧបសម្ព័ន្ធ ក ដែលបានភ្ជាប់ជាមួយ ជាបញ្ជីសាក្សីទាំងអស់ដែលត្រូវបានជ្រើសរើសដោយសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា ដើម្បីគាំទ្រការចោទប្រកាន់អំពីអត្ថិភាពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់មុខសញ្ញាអតីតមន្ត្រី ឬទាហានសាធារណរដ្ឋខ្មែរ ("សាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា")។ សាក្សីទាំងនេះ ត្រូវបានជ្រើសរើស ដោយផ្អែកលើភ័ស្តុតាងដែលបានលើកឡើងទាក់ទងនឹងការចោទប្រកាន់មួយចំនួននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណើរបស់ព្រះរាជអាជ្ញាដើម្បីស្តាប់សក្ខីកម្ម និងដាក់ចូលជាភ័ស្តុតាង។

**6.** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកឡើងពីការចោទប្រកាន់មួយចំនួនពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើអតីតមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។ ក្នុងនោះ ការចោទប្រកាន់ខ្លះ ជាទូទៅពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់មុខសញ្ញាអតីតមន្ត្រី ឬទាហានសាធារណរដ្ឋខ្មែរ[7]។ ចំណែកឯការចោទប្រកាន់ផ្សេងទៀត ត្រូវបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងទីកន្លែងឧក្រិដ្ឋកម្មជាក់លាក់[8]។ ក្រុមមេធាវីការពារក្តី យល់ឃើញថាចម្លើយសាក្សីណាដែលត្រូវបានលើកឡើងថាជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ណាមួយក្នុងចំណោមការចោទប្រកាន់ទាំងនេះ ត្រូវបានសន្និដ្ឋានថាជាប់ពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់មុខសញ្ញាអតីតទាហាន និង/ឬមន្ត្រីសាធារណរដ្ឋខ្មែរ។ អាស្រ័យហេតុនេះ សាក្សីនីមួយៗ ត្រូវមានឈ្មោះនៅក្នុងបញ្ជីឧបសម្ព័ន្ធ ក។ ការចោទប្រកាន់ផ្សេងទៀត

---

ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានផ្តល់សក្ខីកម្មផ្ទាល់មាត់" ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣។ បញ្ជីទាំងបីនេះរួមបញ្ចូលគ្នារួមមានចម្លើយចំនួន ១.៥៧២ មុនពេលពិចារណាទៅដល់ចម្លើយដែលត្រួតគ្នា។

7. *សូមមើល* ឯកសារលេខ **D427** "ដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ") ជើងទំព័រលេខ ៦៩៨, ៧០៩ ដល់ ៧១៤, ៣០០៤ ដល់ ៣០០៥, ៣០១៤។

8. *សូមមើល* ដីកាដំណោះស្រាយ, ជើងទំព័រ ៤៤៧ ដល់ ៤៤៩, ៨៦០ ដល់ ៨៦៧, ៩២១ ដល់ ៩២៣, ៩៦៤ ដល់ ៩៦៥, ២០៦៨, ២១៥៦ ដល់ ២១៦០, ២២៦៣, ២៩៩២។

ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងមន្ត្រី ឬទាហានសាធារណរដ្ឋ ប៉ុន្តែមិនលើកឡើងថា អ្នកទាំងនោះត្រូវបានកំណត់មុខសញ្ញាឡើយ[9]។ សាក្សីដែលត្រូវបានអះអាងថាផ្តល់ការគាំទ្រការចោទប្រកាន់ទាំងនេះ មិនត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធ ក ឡើយ។

**7.** សហព្រះរាជអាជ្ញា បានដាក់សារណាសង្ខេបអំពីសាក្សីពាក់ព័ន្ធនឹងសំណើសុំឱ្យពួកគាត់ផ្តល់សក្ខីកម្មដោយផ្ទាល់ នៅដើមឆ្នាំ ២០១១[10] និងសំណើដែលបានកែប្រែមួយដើម្បីដាក់ចម្លើយសាក្សី និងពាក្យបណ្តឹងជាភស្តុតាង ក្នុងខែ មេសា ឆ្នាំ ២០១៣[11]។ សំណើទាំងពីរនេះ ពិពណ៌នាអំពីភាពជាប់ពាក់ព័ន្ធនៃសាក្សីនីមួយៗទាក់ទងនឹងការចោទប្រកាន់ក្នុងសំណុំរឿង០០២។ សាក្សីណាដែលត្រូវបានអះអាងយ៉ាងច្បាស់ថាមានភស្តុតាងពាក់ព័ន្ធនឹងមន្ត្រី ឬទាហានសាធារណរដ្ឋខ្មែរ និងសាក្សីណាដែលត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានដាក់បញ្ចូលផងដែររួចហើយក្នុងឧបសម្ព័ន្ធ ក ។

**8.** ក្រុមមេធាវីការពារក្តី កត់សម្គាល់ថាសាក្សីមួយចំនួនពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ។ សំណើជាបន្ទាន់ ត្រូវបានធ្វើឡើងដើម្បីស្នើឱ្យសាក្សីផ្តល់សក្ខីកម្ម។ អាស្រ័យហេតុនេះ សាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ ត្រូវបានកំណត់អត្តសញ្ញាណក្នុងបញ្ជីដាច់ដោយឡែកមួយក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ។ សាក្សីទាំងឡាយណាដែលគេដឹងថាបានទទួលមរណភាព ត្រូវបានលុបឈ្មោះចេញពីឧបសម្ព័ន្ធ។ សាក្សីដែលត្រូវបានស្នើសុំរួចហើយក្នុងសំណើដែលពាក់ព័ន្ធ ក៏ត្រូវលុបឈ្មោះចេញផងដែរ[12]។

## III. ឧទ្ធរណ៍

---

9. *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ, ជើងទំព័រ ១៥៧៧, ២០៦៧, ២១៦៨។

10. ឯកសារលេខ **E13.1** "សេចក្តីសង្ខេបព័ត៌មានស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញពីចំណុចនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ក.ស.ព" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

11. ឯកសារលេខ **E278.3** "ឧបសម្ព័ន្ធ ១២ កែប្រែ៖ ចម្លើយរបស់សាក្សី" ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣; ឯកសារលេខ **E278.4** "ឧបសម្ព័ន្ធ ១៣ កែប្រែ៖ បណ្តឹង" ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣។

12. *សូមមើល* កថាខណ្ឌ ៣ *ខាងលើ*។ ឧបសម្ព័ន្ធក៏បង្ហាញផងដែរនូវចម្លើយនានាដែលបានដកស្រង់ចេញពី និង/ឬ បណ្តឹងនានាដែលសាក្សីនីមួយៗបានដាក់។ បញ្ជីឯកសារទាំងនេះគឺសម្រាប់ជាគោលបំណងនៃការកំណត់អត្តសញ្ញាណ និងមិនមានបំណងបង្ហាញឱ្យបានពេញលេញ ក្នុងកាលៈទេសៈដែលសាក្សីបានផ្តល់ចម្លើយច្រើនដង។

## ក. មិនមានភ័ស្តុតាងដោយផ្ទាល់ដែលអាចជឿជាក់បាននៃគោលនយោបាយសម្លាប់ទាហាននិងមន្ត្រីសាធារណរដ្ឋខ្មែរឡើយ

9. ដូចក្រុមមេធាវីការពារក្តីបានលើកឡើងពេលមុនហើយថា[13] ភ័ស្តុតាងដោយផ្ទាល់ដែលថាបក្សកុម្មុយនីស្តកម្ពុជា មានគោលនយោបាយសម្លាប់ទាហាននិងមន្ត្រីសាធារណរដ្ឋខ្មែរ ស្ទើរតែមិនមាន។ ភ័ស្តុតាងច្បាស់លាស់បំផុតនៃគោលបំណងរបស់មជ្ឈិមបក្ស ត្រូវបានផ្តល់ដោយសាក្សីមួយរូបដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយ នួន ជា។ សាក្សីរូបនោះ អះអាងថានៅចាំច្បាស់សម្តីរបស់គាត់នៅក្នុងឱកាសជាក់លាក់មួយ និងបដិសេធយ៉ាងច្បាស់ថាមិនមានគោលនយោបាយនោះឡើយ[14]។ អៀង សារី អះអាងថាមានគោលនយោបាយនោះ ប៉ុន្តែគាត់បានទទួចភ្លាមៗថាគាត់មិនបានដឹងអ្វីអំពីគោលនយោបាយនោះទេ[15]។ មិនមានភ័ស្តុតាងជារូបវន្តណាមួយដែលបង្ហាញថាទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ឡើយ។ មិនមានរណ្តៅសពរួម និងមិនមានសាកសពឡើយ។ មិនមានការវិភាគបែបនីតិបច្ចេកវិទ្យាឡើយ។

10. សាក្សីសំខាន់ៗជាច្រើនរូប បានផ្តល់សក្ខីកម្មបញ្ជាក់ថាទាហាន លន់ ណល់ ចាញ់សង្គ្រាម មិនត្រូវបានសម្លាប់ទេ ប៉ុន្តែត្រូវបានចាប់ដាក់គុក។ ភី ភួន ដែល Phillip Short យកមកសំអាង ជាច្រើនលើកច្រើនសារជាប្រភពដោយផ្ទាល់តែមួយគត់ទាក់ទងនឹងគោលនយោបាយសម្លាប់អតីតទាហានលន់ ណុល បានផ្តល់សក្ខីកម្មដូចខាងក្រោមនេះ៖

> អត់មានទេ ព្រោះគេលើកទង់សហើយ។ <u>មានសេចក្តីណែនាំច្បាស់ថាកុំប៉ះពាល់គេ</u> ពេលសង្គ្រាមនៅសមរភូមិគឺផ្សេង ឥឡូវគេចុះចាញ់យើងហើយ យើងមិនត្រូវប៉ះពាល់គេទេ មានតែស្វាគមន៍អបអរសាទរ និងជួយគេ ឆ្លើយនឹងសំណួរផ្សេងៗដែលគេសួរយើង។

---

13. ឯកសារលេខ **E1/219.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៣ ("សវនាការឆ្លើយតបទៅនឹងការបង្ហាញឯកសារ") ទំព័រ ៤៥:១៥ ដល់ ៤៧:៧ (ភាសាអង់គ្លេស)។

14. *សូមមើល* ឯកសារលេខ **E291** "សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ" ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣, កថាខណ្ឌ ៣១ ដល់ ៣៣។

15. ឯកសារលេខ **IS20.6** "ការសម្ភាសន៍ អៀង សារី របស់លោក Steve Heder" ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៥ ដល់ ៦ (ភាសាអង់គ្លេស)។

คាត់និយាយថា "ខ្មែរដូចគ្នា" កុំឱ្យប៉ះពាល់សោះ។ នេះជាសំដីរបស់ ប៉ុល ពត។[16](គូស បញ្ជាក់បន្ថែម)

សក្ខីកម្មស្រដៀងគ្នានេះ ត្រូវបានបញ្ជាក់ឡើងវិញដោយសាក្សីរូបនេះ និងសាក្សីជាច្រើនទៀត ក្នុងអំឡុងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។[17] ជាក់ស្តែង កងទ័ពបដិវត្តន៍កម្ពុជាដែលបាន ចូលរួមក្នុងការជម្លៀសទីក្រុងភ្នំពេញ បានផ្តល់សក្ខីកម្មស៊ីសង្វាក់គ្នាថាទាហានសាធារណរដ្ឋខ្មែរ មិនមានទុក្ខទោសឡើយ នៅពេលពួកគេសុំចុះចាញ់នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ឬមុនឬក្រោយ បន្តិច។[18]

11. សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា បានកំណត់ឯកសារភស្តុតាងដែលបានជ្រើស រើសមួយចំនួនតូចដើម្បីគាំទ្រការអះអាងរបស់ខ្លួនអំពីអត្ថិភាពនៃគោលនយោបាយសម្លាប់អតីត ទាហាន និងមន្ត្រីរបប លន់ ណុល។ ឯកសារទាំងនេះមួយចំនួន ត្រូវបានពិពណ៌នាដោយសហ ព្រះរាជអាជ្ញា ក្នុងអំឡុងសវនាការដាក់បង្ហាញឯកសារ ហើយត្រូវបានជំទាស់ភ្លាមៗដោយក្រុម មេធាវីការពារ[19]។ ស្រដៀងគ្នានេះ ឯកសារផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតយកមក សំអាង ត្រូវបានពិនិត្យឃើញថាមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។ សហចៅក្រមស៊ើបអង្កេត បានដកស្រង់អត្ថបទសារព័ត៌មានមួយចំនួន ដែលពិពណ៌នាអំពីព័ត៌មានស៊ើបការណ៍របស់សហរដ្ឋ

---

16. ឯកសារលេខ **E3/24** កំណត់ជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ វីជាម តុន ហៅ ភី ភួន, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៧, ទំព័រ ៥។

17. *សូមមើលឧទាហរណ៍* ឯកសារលេខ **E1/98.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ ("សក្ខីកម្មរបស់ ភី ភួន"), ទំព័រ ៨៨:២ ដល់ ១០ (ភាសាអង់គ្លេស); ឯកសារលេខ **E1/193.1** "ប្រតិចារឹកនៃកិច្ច ដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ("សក្ខីកម្មរបស់ អៀង ផាន") ទំព័រ ៣៦:៩ ដល់ ៤៣:៩, ៦៥:២០ ដល់ ៧១:២០ (ភាសាអង់គ្លេស); ឯកសារលេខ **E1/129.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១២ ("សក្ខីកម្មរបស់ មាស វឿន"), ទំព័រ ៩៧:១ ដល់ ១២ (ភាសាអង់គ្លេស); ឯកសារលេខ **E1/139.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ ("សក្ខីកម្មរបស់ គង់ គីម") ទំព័រ ៥០:១៨ ដល់ ៥:១៣ (ភាសាអង់គ្លេស); ឯកសារលេខ **E1/177.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ ("សក្ខីកម្មរបស់ ឆោម សែ"), ទំព័រ ៦៤:១៤ ដល់ ៦៥:១ (ភាសាអង់គ្លេស)។

18. *សូមមើល* ជើងទំព័រ ១៦ *ខាងលើ*។

19. សវនាការឆ្លើយតបទៅនឹងការបង្ហាញឯកសារ, ទំព័រ ៥៣:២២ ដល់ ៧៥:៥។

អាមេរិក ដែលពិពណ៌នាអំពីបញ្ហាដែលស៊ើបការណ៍បានពីខ្មែរក្រហមពាក់ព័ន្ធនឹងអតីតទាហាន និង មន្ត្រីសាធារណរដ្ឋខ្មែរ[20]។ អ្នករៀបរៀងព័ត៌មានចចាមអារ៉ាមមិនផ្ទាល់ (អត្ថបទសារព័ត៌មាន), អ្នករៀបរៀងព័ត៌មានចចាមអារ៉ាមដោយផ្ទាល់ (របាយការណ៍ចារកម្ម) ឬប្រភពដើម ("បទបញ្ជា" ជាភាសាខ្មែរ) មិនបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយមិនមានភ័ស្តុតាងបង្ហាញថា អ្នកណាជាអ្នកចេញ "បញ្ជា" ឬអ្នកណាទទួលបញ្ជានោះទេ។ សារទូរលេខមួយចម្លងជូន នួន ជា ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៧៦ រយៈពេលជិតមួយឆ្នាំក្រោយព្រឹត្តការណ៍ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅទួលពោធិ៍ជ្រៃ យោងដោយប្រយោលតែម្តងគត់ទៅលើ "អតីតទាហាន" ជាខ្មាំង ដោយមិនមានការបញ្ជាក់ ឬបញ្ជាក់ច្បាស់ថាពួកគេត្រូវបាន ឬប្រហែលជាត្រូវបានសម្លាប់ឡើយ។[21] មិនមានភ័ស្តុតាងផ្ទាល់ ត្រូវបានដាក់ដោយសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាឡើយ។

### ខ. ចម្លើយសាក្សីដែលអះអាងថាពិពណ៌នាអំពីការសម្លាប់ទាហាននិងមន្ត្រីសាធារណរដ្ឋខ្មែរ មិនអាចជឿជាក់ជាប្រព័ន្ធឡើយ

12. ដោយហេតុថាស្ទើរតែមិនមានភ័ស្តុតាងផ្ទាល់ណាមួយសោះនោះ សញ្ញាណដែលថាមានគោលនយោបាយសម្លាប់អតីតទាហាន និងមន្ត្រីលន់ ណល់ ទំនងជាផ្អែកជាបឋមលើការអះអាងដែលថាការសម្លាប់បានរាលដាលយ៉ាងខ្លាំងពាសពេញប្រទេសកម្ពុជា ដែលការសម្លាប់នោះ ប្រាកដជាបានអនុវត្តតាមគោលនយោបាយមួយបង្កើតដោយមជ្ឈិមបក្ស[22]។ សក្ខីកម្មដែលអះអាងថាពិពណ៌នាហេតុការណ៍នីមួយៗនៃការសម្លាប់នោះ ជាពិសេស សក្ខីកម្មពីសាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា មានភាពសំខាន់បំផុត។ ទោះជាយ៉ាងនេះក្តីការពិនិត្យមើលដោយប្រុងប្រយ័ត្ននៃចម្លើយទាំងនោះ បង្ហាញថាចម្លើយទាំងនេះ មិនអាចជឿជាក់បានជាប្រព័ន្ធ និងមិនគាំទ្រជំហររបស់

---

20. ដីកាដំណោះស្រាយ, ជើងទំព័រ ៧១២ (ដោយដកស្រង់ប្រភពឯកសារដែលពាក់ព័ន្ធ)។

21. ឯកសារលេខ E3/511 ទូរសាររបស់ ប.ក.ក ផ្ញើដោយ ពក ដែលមានចំណងជើងថា៖ "ទូរសាលេខ ៩៤ - ខ្ទង់ ១១០០ - គោរពជូនបង ប៉ុល ជាទីស្រឡាញ់" ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៧៦។

22. *សូមមើលឧទាហរណ៍* ឯកសារលេខ E1/191.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ ១៣០:២៣ ដល់ ១៣៣:៣ (ភាសាអង់គ្លេស)។

ព្រះរាជអាជ្ញាឡើយ។

13. ទីមួយ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ខកខានមិនអាចកំណត់អត្តសញ្ញាណសាក្សីច្រើនជាងបួនរូប ដែលអះអាងថាបានមើលឃើញការសម្លាប់អតីតទាហាន ឬមន្ត្រីនោះបានឡើយ។ ការខកខាននោះ គួរឲ្យកត់សម្គាល់យោងទៅលើសេចក្តីសន្និដ្ឋាន ដែលខ្លួនជម្រុញឲ្យអង្គជំនុំជម្រះថាការសម្លាប់នោះ បានរាលដាល និងកើតឡើងគ្រប់ទីកន្លែងដោយគ្មានភ័ស្តុតាងដោយផ្ទាល់បញ្ជាក់ថាការសម្លាប់នោះ ច្បាស់ជាចេតនារបស់មជ្ឈិមបក្សឡើយ។ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា និងអ្នកតំណាងរបស់ខ្លួនជាច្រើននាក់ បានសម្ភាសរាប់ពាន់ដងជាមួយមនុស្សគ្រប់ជាន់ថ្នាក់នៃរបបកម្ពុជាកម្ពុជាប្រជាធិបតេយ្យទូទាំងប្រទេសកម្ពុជា។ ការដែលស្ទើរតែមិនមានអ្នកណាម្នាក់បានឃើញដោយផ្ទាល់នូវការសម្លាប់ជាក់ស្តែង គប្បីអង្គជំនុំជម្រះយកមកពិចារណាជាកត្តាដ៏សំខាន់មួយក្នុងការវាយតម្លៃទៅលើភ័ស្តុតាង។

14. ទម្រង់មួយនៃការសម្លាប់ មិនអាចទាញសន្និដ្ឋានពីសក្ខីកម្មដែលត្រូវបានកំណត់ និងមានលក្ខណៈសើសើដែលសាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា បានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។ សាក្សីមួយចំនួន ផ្តល់សក្ខីកម្មថាទាហាន និងមន្ត្រីរបប លន់ ណុល ត្រូវបានកម្មាភិបាលបក្សកុម្មុយនីស្តបំបែកចេញពីក្រុមធំ ហើយត្រូវបានបញ្ជូនចេញ។ ទោះជាយ៉ាងនេះក្តី មិនមានសាក្សីណាម្នាក់ ដឹងដោយផ្ទាល់អំពីអ្វីដែលបានកើតឡើងបន្ទាប់ពីពេលនោះឡើយ។ វាអាចមានលទ្ធភាពនៃហេតុការណ៍ដែលអាចកើតឡើងនៅពេលបន្ទាប់នោះ រួមមាន ការបញ្ជូនទៅការដ្ឋាន ឬសហករណ៍ ឬបញ្ជូនទៅរៀនសូត្រ ឬឃុំឃាំងនៅមន្ទីរសន្តិសុខណាមួយ។ ជាក់ស្តែង ភ័ស្តុតាងនេះ ស្របទៅនឹងការអះអាងរបស់លោក ហេង សំរិន ដែលថាមន្ត្រីរបប លន់ ណុល ត្រូវបាន "ដកចេញពីក្របខណ្ឌ" ជាជាងត្រូវបានសម្លាប់[23]។ ដូចក្រុមមេធាវីការពារក្តី បានលើកឡើងក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការដាក់ឯកសាររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់នេះថាមានហេតុផលគ្រប់គ្រាន់ដែលត្រូវសង្ស័យចំពោះកិច្ចប្រឹងប្រែង

23. *សូមមើល* ឯកសារលេខ **E291** "សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ" ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១៣, កថាខណ្ឌ ៣១ ដល់ ៣៣។

របស់សហព្រះរាជអាជ្ញាដើម្បីយល់ឃើញថាការដកចេញ ឬការបាត់ខ្លួនជាការយកទៅសម្លាប់[24]។

15. ភស្តុតាងដទៃទៀត គឺកាន់តែមានលក្ខណៈស្រាលថែមទៀត។ ចម្លើយមួយចំនួនបញ្ជាក់ប្រាប់ឡើងវិញនូវពាក្យចចាមអារ៉ាមកាលពីយូរយារមកហើយ ដែលជាទូទៅទទួលបានពីប្រភពមិនច្បាស់លាស់ ដែលសាក្សីទាំងនោះបានស្គាល់មនុស្សមួយចំនួនដែលធ្លាប់មានតួនាទីនៅក្នុងរបបមុន ហើយមនុស្សទាំងនោះត្រូវបានចាប់ខ្លួន "បាត់ខ្លួន" ឬ សម្លាប់ចោល។ មិនមានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះដឹងដោយខ្លួនឯងផ្ទាល់អំពីការប្រព្រឹត្តណាមួយចំពោះអតីតមន្ត្រី និងទាហាននោះឡើយ ចុះទម្រាំតែការសម្លាប់អ្នកទាំងនោះទៀតនោះ។ លើសពីនេះទៀត ចម្លើយជាច្រើនក្នុងចំណោមចម្លើយទាំងនេះ ពុំមានមូលដ្ឋានទាល់តែសោះសម្រាប់យកមកធ្វើសេចក្តីសន្និដ្ឋានថាជនរងគ្រោះទាំងនេះ ត្រូវបានកំណត់មុខសញ្ញាដោយសារតែធ្លាប់ជាសមាជិកនៃរបបមុន ប្រសិនបើពួកគេពិតជាត្រូវបានសម្លាប់មែននោះ។ សាក្សីដទៃទៀត គ្រាន់តែពិពណ៌នាអំពីការឮអ្នកដទៃទៀតនិយាយចាត់ទុកមន្ត្រីនៃរបបមុនថាជា "ខ្មាំង" ប៉ុណ្ណោះ ឬប្រើពាក្យទូទៅថា មនុស្សទាំងនោះគួរតែសម្លាប់ចោល។ សាក្សីដទៃទៀតអះអាងថា បានឃើញសាកសព ប៉ុន្តែពុំមានព័ត៌មានអំពីថាតើពួកគេត្រូវបានសម្លាប់បែបណានោះឡើយ។ ពិតណាស់ នៅក្នុងករណីមួយចំនួន វាមានលក្ខណៈមិនច្បាស់ថាតើពួកគាត់ស្គាល់ជនរងគ្រោះទាំងនោះថាជាអតីតមន្ត្រី ឬទាហានលន់ ណុល ដោយរបៀបណា។ នៅក្នុងករណីមួយចំនួនទៀត វាច្បាស់ណាស់ថាពួកគេជាទាហាន ដោយសារតែពួកគេទើបតែត្រូវបានសម្លាប់នៅក្នុងសមរភូមិ។ នៅក្នុងករណីមួយចំនួនទៀត មូលដ្ឋាននៃអំណះអំណាងរបស់សាក្សីដែលថា មន្ត្រី ឬទាហាន លន់ ណុល ត្រូវបានសម្លាប់នោះ គឺមានភាពមិនច្បាស់លាស់ទាល់តែសោះ។ នៅក្នុងករណីខ្លះទៀត ពុំមានការយោងបញ្ជាក់ណាមួយឡើយទៅលើមន្ត្រី ឬទាហាន លន់ ណុល ឬប្រសិនបើមានការយោងបញ្ជាក់មែននោះ ក៏ពុំមានការអះអាងថាពួកគេត្រូវបានសម្លាប់ឡើយ។

16. លក្ខណៈមិនច្បាស់លាស់នៃចម្លើយទាំងនេះ បង្ហាញឱ្យឃើញថាចម្លើយទាំងនេះមានសភាពមិនគួរឱ្យជឿជាក់បានឡើយ។ ប៉ុន្តែ ហានិភ័យដែលពាក់ព័ន្ធនឹងការផ្អែកទៅលើចម្លើយទាំងនេះដោយមិន

24. សវនាការឆ្លើយតបទៅនឹងការបង្ហាញឯកសារ, ទំព័រ ៤៧:១៤ ដល់ ៥១:៦។ *សូមមើលផងដែរ* សេចក្តីព្រាងប្រតិចារឹក (ភាសាអង់គ្លេស), ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥:២១ ដល់ ៥:១៧ (បើតាមសំដីលោក Stehen Heder ពាក្យថា "ដក" ("removal") អាចមានន័យជាអំពីជាក់លាក់មួយចំនួនរួមមាន ការចាប់ខ្លួន ឬដកចេញពីតំណែង)។

មានការសួរដេញដោលនោះ បានលេចចេញយ៉ាងច្បាស់ក្រឡែតក្នុងអំឡុងការសួរដេញដោល។ ឧទាហរណ៍ថ្មីៗនេះ សាក្សីពីរនាក់ ដែលសហព្រះរាជអាជ្ញាបានស្នើឡើងសម្រាប់គោលបំណងជាពិសេសក្នុងការរៀបរាប់អំពីការសម្លាប់អតីតមន្ត្រី ឬទាហានរបស់របបសាធារណរដ្ឋខ្មែរ បានឡើងមកផ្តល់សក្ខីកម្មនៅសប្តាហ៍ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣។ សាក្សីទាំងពីរនាក់នេះ និយាយផ្ទុយទៅនឹងភ័ស្តុតាងនៅក្នុងចម្លើយរបស់ពួកគាត់ដែលបានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត ដោយពួកគាត់បានផ្តល់សក្ខីកម្មថា ពួកគាត់ពុំបានដឹងដោយផ្ទាល់ខ្លួនឯងឡើយអំពីអង្គហេតុដែលពាក់ព័ន្ធ និងបានទទួលស្គាល់ថា អង្គហេតុដែលពួកគាត់បានអះអាងថាបានដឹងនោះ គឺជាពាក្យចចាមអារ៉ាម និងជាការសន្និដ្ឋាន។

17. សាក្សីទីមួយ ឈ្មោះ ពេជ្រ ជឹម បានធ្វើសក្ខីកម្មនៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣។ ពេជ្រ ជឹម បានបញ្ជាក់នៅក្នុងចម្លើយរបស់គាត់ដែលផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេតថា អតីតមន្ត្រី និងទាហាន លន់ ណុល ត្រូវបានកម្មាភិបាលខ្មែរក្រហមជ្រើសយកចេញពីក្នុងចំណោមក្រុមមនុស្សយ៉ាងច្រើនក្នុងអំឡុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយត្រូវបានគេសម្លាប់ចោល[25]។ ប៉ុន្តែ ក្នុងអំឡុងការសួរដេញដោល គាត់បានពន្យល់ថា គាត់ "ពុំបានឃើញព្រឹត្តិការណ៍នោះដោយខ្លួនគាត់ផ្ទាល់ឡើយ" ហើយ "ទាក់ទិននឹងជោគវាសនារបស់ទាហានទាំងនោះ ខ្ញុំមិនដឹងទេ"[26]។ លោក ពេជ្រ ជឹម ទទួលស្គាល់ថា ប្រភពតែមួយគត់នៃព័ត៌មានដែលគាត់ទទួលបាននេះ គឺពីប្រពន្ធរបស់ទាហានដែលត្រូវបានអះអាងថាយកទៅសម្លាប់ចោល[27]។ ជាលទ្ធផល ប្រភពទាំងនោះដឹងត្រឹមតែថា ពួកគាត់ត្រូវបានគេបំបែកចេញពីប្តីរបស់ពួកគាត់ ក្នុងអំឡុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[28]។ គាត់បានពន្យល់ថា៖

---

[25] ឯកសារលេខ E-1/215.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 32:17-25។

[26] ឯកសារលេខ E-1/215.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 57:25, 58:13-18 ។

[27] ឯកសារលេខ E-1/215.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 57:1-16 ។

[28] ឯកសារលេខ E-1/215.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 32:17-25 ។

ខ្ញុំមិនបានឃើញផ្ទាល់ភ្នែក ហើយមិនបានរួមចំណែកធ្វើ។ ដឹងនេះ ឮតាមត្រចៀក ពីមាត់មួយ ទៅមាត់មួយ ខ្សឹបតៗគ្នាអញ្ចឹងទៅ[29]។

លោក ជឹម បានសន្និដ្ឋានបញ្ចប់ផ្នែកនៃសក្ខីកម្មរបស់គាត់ដោយអះអាងថា គាត់មិនដែលបានឃើញការសម្លាប់អតីតមន្ត្រី ឬទាហាន លន់ ណុល[30] មិនដែលមានគេប្រាប់គាត់ថាពួកគេបានសម្លាប់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ[31] ហើយថា ព័ត៌មានដែលគាត់ទទួលបាន ទាក់ទិននឹងការបាត់ខ្លួនអតីតទាហាន លន់ ណុល គឺផ្អែកទៅលើពាក្យចចាមអារ៉ាម និងការសន្និដ្ឋាន[32]។

18. សាក្សីទីពីរ ឈ្មោះ ឡេវ ឡាំ បានធ្វើសក្ខីកម្មនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣។ នៅពេលសហព្រះរាជអាជ្ញាសួរអំពីថាតើ អតីតសមាជិករបស់របបសាធារណរដ្ឋខ្មែរត្រូវបានគេជ្រើសរើសដាក់ជាក្រុមដោយឡែក និងបំបែកចេញពីប្រជាជនផ្សេងៗទៀត ឬយ៉ាងណា នៅពេលដែលពួកគេបានមកដល់ក្នុងឃុំរបស់គាត់ បន្ទាប់ពីត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញនោះ លោក ឡាំ បានបញ្ជាក់ថា៖ “ពេលដែលគេរើសហ្នឹង ខ្ញុំមិនបានដឹងទេ”[33]។ ហើយ ឡេវ ឡាំ ក៏មិនបានដឹងផងដែរអំពីរបៀបដែលគេកំណត់ថាជាអតីតមន្ត្រី និងទាហាន លន់ ណុល ពីក្នុងចំណោមអ្នកជម្លៀសផ្សេងៗទៀតនោះ នៅពេលដែលពួកគេត្រូវបានគេប្រមូលផ្តុំ ឬថាតើ ចុងក្រោយ ជីវិតពួកគេនឹងទៅជាយ៉ាងណានោះ[34]។ នៅពេលសួរគាត់ថាតើ គាត់ដឹងដែរឬទេថា មន្ត្រី លន់ ណុល ហ្នឹងចង់សំដៅថាម៉េចដែរ គាត់ឆ្លើយថា “អារឿងហ្នឹង ខ្ញុំមិនដឹងទេ”[35]។

---

[29] ឯកសារលេខ E-1/215.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 57:9-12 ។

[30] ឯកសារលេខ E-1/215.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 60:1-7 ។

[31] ឯកសារលេខ E-1/215.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 60:9-12 ។

[32] ឯកសារលេខ E-1/215.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 58:19-59:6 ។

[33] ឯកសារលេខ E-1/216.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 22:18-23:1 ។

[34] ឯកសារលេខ E-1/216.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 68:8-12, 72:22-73:7

[35] ឯកសារលេខ E-1/216.1 “ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ” ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 65:12-15 ។

19. ស្រដៀងគ្នានេះដែរ នៅពេលសួរដេញដោលទៅលើការពិពណ៌នាដែលមាននៅក្នុងចម្លើយរបស់គាត់ដែលបានផ្តល់ទៅឱ្យសហចៅក្រមស៊ើបអង្កេតអំពីការសម្លាប់សមាជិកគ្រួសារ និងអ្នកដែលជាប់ពាក់ព័ន្ធនឹងអតីតរបប លន់ ណុល មួយក្រុមដែលមានចំនួន ២០នាក់នោះ គាត់បានពន្យល់ថា៖ "ទេ ខ្ញុំមិនបានឃើញទេ គ្រាន់តែយកទៅហ្នឹងមានគេចាំទទួលនៅទីនោះបាត់ហើយ ហើយគេឱ្យខ្ញុំមកវិញ"[36]។ នៅពេលដែលប្រឈមជាមួយនឹងចម្លើយពីមុនរបស់គាត់ដែលថា គាត់បានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់ក្រុមគ្រួសារអ្នកជម្លៀសនៃអតីតមន្ត្រី និងទាហាន លន់ ណុល ចំនួន ១០០នាក់នោះ គាត់បានបញ្ជាក់ប្រាប់ថា គាត់មិនបានឃើញការសម្លាប់នោះទេ និងមិនដឹងថាតើរឿងនេះបានកើតឡើងមែន ឬយ៉ាងណានោះឡើយ[37]។ វិសាលភាពនៃការដឹងដោយខ្លួនគាត់ផ្ទាល់ថា ការសម្លាប់នោះបានកើតឡើង គឺថា គាត់បានឮគេរាប់ "មួយ ពីរ បី"[38]។

20. សាក្សីផ្សេងៗទៀត ដែលមានឈ្មោះនៅក្នុងបញ្ជីឧបសម្ព័ន្ធ ក ដែលបានធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះ បានទទួលស្គាល់ស្រដៀងៗគ្នាជាច្រើនលើក នៅពេលមានការសួរដេញដោល។ ហ៊ុន ឈុនលី បានពន្យល់ថា ទោះបីជាគាត់បានឮថា នាយទាហានត្រូវបានគេដឹកយកចេញទៅហើយក្រោយមកត្រូវបានសម្លាប់ចោលយ៉ាងណាក៏ដោយ ក៏គាត់មិនដែលបានឃើញព្រឹត្តិការណ៍ណាមួយនោះឡើយ[39]។ ប៉ែជុយ ជីបសែ បានផ្តល់សក្ខីកម្មថា ទាហាន លន់ ណុល ត្រូវបានគេនាំយកទៅកំពង់ក្តី ហើយក្រោយមកត្រូវបានគេសម្លាប់ចោល ប៉ុន្តែថា គាត់មិនបានឃើញដោយផ្ទាល់ភ្នែកនូវការជម្លៀសទៅកំពង់ក្តី និងការសម្លាប់ដែលគេអះអាងថាកើតមាននោះឡើយ[40]។ គឹម វ៉ាន់ឌី បានបញ្ជាក់ថា គាត់បានឃើញសាកសពទាហាន លន់ ណុល ដែល "ស្លាប់ហ្នឹង ខ្ញុំគិតថាប្រហែលជាបាញ់គ្នាហើយ ដោយសារបាញ់គ្នាហើយបានស្លាប់ ពីព្រោះខ្មោចហ្នឹងហើមហើយ ហើមឡើង

---

[36] ឯកសារលេខ E-1/216.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 77:14-21 ។

[37] ឯកសារលេខ E-1/216.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 82:12-83:18 ។

[38] ឯកសារលេខ E-1/216.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 87:11-88:15 ។

[39] ឯកសារលេខ E-1/150.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ 56:19-57:18 ។

[40] ឯកសារលេខ E-1/140.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ 25:22-27:11, 30:8-16 ។

វុយ រោមអ៊ូ"[41]។ ស៊ុំ ជា បានផ្ដល់សក្ខីកម្មថា គាត់ពុំមានភ័ស្តុតាងផ្ទាល់អំពីការសម្លាប់ណាមួយឡើយ[42]។ គង់ គីម, មាស វឿន និង អៀង ផាន អ្នកទាំងអស់នេះបានឆ្លើយផ្ទុយទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដោយផ្ទាល់តែម្ដង ដោយពន្យល់ថា ទាហាន លន់ ណុល ដែលបានចុះចាញ់នៅក្នុងវាយប្រយុទ្ធគ្នា បានរួចខ្លួន[43]។ សហព្រះរាជអាជ្ញាអះអាងថា អ៊ុំង ឆាត់ និង លឹម សាត បានឆ្លើយផ្ទុយទៅនឹងផ្នែកជាច្រើននៃចម្លើយពីមុនរបស់ពួកគាត់ក្នុងអំឡុងពេលសួរដេញដោល ហើយពិតណាស់មិនមាននរណាម្នាក់ក្នុងចំណោមពួកគាត់នេះបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកឡើយ[44]។ គ្រប់សាក្សីផ្សេងៗទៀតដែលមានឈ្មោះនៅក្នុងបញ្ជីឧបសម្ពន្ធ ក ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ បានផ្ដល់សក្ខីកម្មស្រដៀងៗគ្នាថា ពួកគាត់បានឮ ឬបានសន្និដ្ឋានថា មន្ត្រី ឬទាហាន លន់ ណុល ត្រូវបានសម្លាប់។ គ្មាននរណាម្នាក់បានឃើញការសម្លាប់ណាមួយដោយខ្លួនឯងផ្ទាល់ឡើយ។

## គ. សាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា ត្រូវតែប្រឈមនឹងការសួរដេញដោល

21. ដោយពិចារណាទៅលើការរៀបរាប់ពីខាងលើ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា មកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ ភ័ស្តុតាងដែលសាក្សីទាំងនេះផ្ដល់ជូន មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការចោទប្រកាន់អំពីអត្ថិភាពនៃគោលនយោបាយក្នុងការសម្លាប់មន្ត្រី និងទាហាន លន់ ណុល។ ភ័ស្តុតាងនោះគឺមានសភាពមិនគួរឱ្យជឿជាក់បានឡើយ និងបានបង្ហាញឱ្យឃើញ ដោយស៊ីសង្វាក់គ្នា នូវភាពកាន់តែមិនគួរឱ្យ

[41] ឯកសារលេខ E-1/148.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ 101:23-102:8 ។

[42] ឯកសារលេខ E-1/140.1 "ប្រតិចារឹកនៃកិច្ចដំណើរការជំនុំជម្រះ" ថ្ងៃទី 5 ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ 113:11-22 ។

[43] សូមមើល ជើងទំព័រ ១៦ ខាងលើ។

[44] សូមមើល ឯកសារ E-291 "សំណើបន្ទាន់ស្នើសុំកោះហៅសាក្សីសំខាន់ៗទាក់ទិននឹងទួលពោធិ៍ជ្រៃ" ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩-១៤។ ឯកសារលេខ **E-1/207.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ 70:15-71:14 ។

ជឿជាក់បានថែមទៀត បន្ទាប់ពីការសួរដេញដោល។ ដូច្នេះ មេធាវីការពារក្ដីស្នើសុំនូវឱកាស ដើម្បីជំទាស់តវ៉ាទៅនឹងភ័ស្ដុតាងរបស់ពួកគាត់នៅក្នុងតុលាការដោយចំហ។

## ឃ. សំណើនេះគឺជា "សំណើថ្មី" និង បំពេញនូវវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

22. សាក្សីភាគច្រើនក្នុងចំណោមសាក្សីដែលមានរាយឈ្មោះនៅក្នុងបញ្ជីឧបសម្ពន្ធ ក មិនធ្លាប់ត្រូវបានស្នើឲ្យផ្ដល់សក្ខីកម្មឡើយកាលពីមុនឡើយ។ ដូច្នេះ សំណើនេះពិតជាបំពេញនូវលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលថា ភ័ស្ដុតាងថ្មី ដែលបានស្នើឡើងបន្ទាប់ពីការចាប់ផ្ដើមការជំនុំជម្រះ "ពុំអាចរកបានឡើយ" កាលពីមុន។ អង្គជំនុំជម្រះក៏អាចសម្រេចជ្រើសយកលក្ខខណ្ឌតម្រូវផងដែរ ដែលថាសំណើនេះគឺជា "សំណើថ្មី" អនុលោមតាមអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣។ មេធាវីការពារក្ដីអះអាងថា សំណើនេះត្រូវបានធ្វើឡើងនៅក្នុងពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដូច្នេះសំណើនេះបំពេញនូវបទដ្ឋានទាំងពីរ។

23. នៅពេលមេធាវីការពារក្ដីបានរៀបចំបញ្ជីឈ្មោះសាក្សីរបស់ខ្លួនពីដំបូងក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ ពុំមានការចង្អុលបង្ហាញថា វិធាននានាពាក់ព័ន្ធនឹងការទទួលយកចម្លើយសាក្សីនៅឯតុលាការ *មិនអចិន្ត្រៃយ៍ទាន*នឹងយកមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះឡើយ។ តាមពិតគោលជំហររបស់មេធាវីការពារក្ដីគឺថា ចម្លើយសាក្សីមិនអាចត្រូវបានទទួលយកឡើយ ប្រសិនបើគ្មានការផ្ដល់ឱកាសឲ្យសួរដេញដោលនៅឯសវនាការនោះ[45] ដែលនេះគឺជាទស្សនមួយដែលត្រូវបានគាំទ្រតាមរយៈការពោលអះអាងយ៉ាងច្បាស់របស់សហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងបញ្ហានេះ និងការបញ្ជាក់យ៉ាងច្បាស់នៃវិធានផ្ទៃក្នុង[46]។ នៅពេលនោះ ពុំមានកាតព្វកិច្ចសម្រាប់ នួន ជា ក្នុងការស្នើសុំសាក្សីបន្ថែម ទាក់ទិននឹងការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ឡើយ។

---

[45] ឯកសារលេខ **E-96/1** "សារណាឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ កសព ទាក់ទិននឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី" ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ១។

[46] សូមមើល វិធាន ៨៤(១)នៃវិធានផ្ទៃក្នុង។ ឯកសារលេខ **A-110/I** អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេត ផ្ញើជូនសហមេធាវី នួន ជា ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ ២។

24. ឱកាសក្រោយៗទៀតត្រូវបានផ្ដល់ឲ្យ ក្នុងការស្នើសុំឲ្យសាក្សីបង្ហាញវត្តមាន ទោះបីជានៅមិនទាន់មានការសម្រេចទៅលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងសំណើសុំឲ្យទទួលយកជាភ័ស្តុតាងនូវចម្លើយសាក្សីយ៉ាងណាក៏ដោយ។ តាមពិត អង្គជំនុំជម្រះបានបញ្ជាក់ជាលើកដំបូងថា ចម្លើយសាក្សី ពាក់ព័ន្ធនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់មុខសញ្ញាអតីតមន្ត្រី និងទាហានរបស់របបសាធារណរដ្ឋខ្មែរនោះ អាចត្រូវបានទទួលយកនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣។ អង្គជំនុំជម្រះក៏បានបញ្ជាក់នៅពេលនោះផងដែរថា សេចក្ដីសម្រេចជាផ្លូវការ ទាក់ទិននឹងបញ្ហានេះ នឹងចេញក្នុងរយៈពេលពីរ ឬបីសប្ដាហ៍ទៀត។

25. ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់រួចហើយខាងលើនេះ វាចាំបាច់ត្រូវតែមានការសួរដេញដោលសាក្សីទាំងនោះ ប្រសិនបើមានការទទួលយកចម្លើយដែលផ្តល់ឲ្យដោយសាក្សីដែលពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា។ នៅមុនថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ពុំមានការចង្អុលបង្ហាញណាមួយថា ចម្លើយសាក្សីទាំងនេះនឹងត្រូវទទួលយកនោះឡើយ។ នៅក្នុងប៉ុន្មានសប្ដាហ៍ចាប់តាំងពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានទន្ទឹងរង់ចាំសេចក្ដីសម្រេចស្ដាពររបស់អង្គជំនុំជម្រះសាលាដំបូង មុននឹងសម្រេចដាក់សំណើនេះ។ ដោយពិចារណាលើការជូនដំណឹងនាពេលថ្មីៗនេះពីអង្គជំនុំជម្រះថា សវនាការលើភ័ស្តុតាងនឹងបិទបញ្ចប់ក្នុងពេលឆាប់ៗខាងមុខនេះ មេធាវីការពារក្តីបានសម្រេចដាក់សំណើនេះមុនសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ សម្រាប់ហេតុផលដូចគ្នានេះដែរ សំណើនេះត្រូវបានដាក់ក្នុងពេលឆាប់ៗបំផុតតាមដែលអាចធ្វើទៅបាន។ ដូច្នេះ សំណើនេះបានដាក់ទាន់ពេលវេលា។

## IV. សេចក្តីសន្និដ្ឋាន និងសំណូមពរ

26. យោងទៅលើហេតុផលទាំងនេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះកោះហៅសាក្សីទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីឧបសម្ពន្ធ ក ដែលមិនទាន់បានបង្ហាញវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។

**សហមេធាវី នួន ជា**

**សុន អរុណ** | **Victor KOPPE**